# សំណួរ

# តើក្នុងករណីណា ដែលវេជ្ជបណ្ឌិត ឬគ្រូពេទ្យ ទទួលខុសត្រូវចំពោះ ផលវិបាកនៃការរំលូតកូន?

## ចម្លើយ

មាត្រា ៨ នៃច្បាប់ ស្តីពី ការរំលូតកូនឆ្នាំ ១៩៩៧ បានចែងនូវលក្ខខ័ណ្ឌស្របច្បាប់នៃការរំលូតកូន។ ប្រសិនបើអនុវត្តតាម នឹងមិននាំឲ្យការទទួលខុសត្រូវទេ ក៏ប៉ុន្តែ ការមិនបានគោរពតាម ជាការបំពានច្បាប់ នឹងនាំឲ្យមានការទទួលខុសត្រូវ។ តើក្នុងស្ថានភាពណា ដែលនាំឲ្យមានការទទួលខុសត្រូវ?

ការទទួលខុសត្រូវក្នុងករណី៖ ១. វេជ្ជបណ្ឌិត មិនទទួលបានការអនុញ្ញាតឲ្យធ្វើការរំលូតកូន តែបានធ្វើ។ ២. ទោះបីមានការអនុញ្ញាត ក៏ប៉ុន្តែប្រសិនបើមិនអនុវត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងមាត្រា ៨។ ៣. ការរំលូត មិនត្រូវបានធ្វើនៅក្នុងទីតាំងអនុញ្ញាត។

ទោសទណ្ឌ មានដូចជា ការព្រមាន លើគ្រូពេទ្យនោះ។ ករណីមិនរាងចាល នឹងបិទទីតាំងដែលធ្វើការរំលូតកូន។ គ្រូពេទ្យក៏នឹងត្រូវទទួលទោសព្រហ្មទណ្ឌ ដាក់ពន្ធនាគារ និងពិន័យ។ ការរំលូតកូន ធ្វើឲ្យស្ត្រីមានគភ៌នោះ ក្លាយជាពិការជន ឬស្លាប់ ទោសនឹងពន្ធនាគារ មានរយៈពេលអតិបរមា រហូតដល់ ១០ ឆ្នាំ (មាត្រា ១២)។